**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខ : ០១៨ សណន

# សេចក្តីណែនាំ
# ស្តីពី
# បែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាល តាមយន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលឃុំ សង្កាត់

អនុលោមមាត្រា២០ មាត្រា២១ មាត្រា២២ និងមាត្រា២៣ នៃអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ រដ្ឋបាលឃុំ សង្កាត់ត្រូវរៀបចំឱ្យមានយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋនៅក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់ខ្លួន។

ដើម្បីធានានូវគុណភាព ប្រសិទ្ធភាព ប្រសិទ្ធផល តម្លាភាព និងគណនេយ្យភាពនៃការផ្តល់សេវារដ្ឋបាលតាមរយៈយន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលឃុំ សង្កាត់ ក្រសួងមហាផ្ទៃសូមធ្វើការណែនាំអំពីបែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលដូចខាងក្រោម៖

## ១. ការរៀបចំយន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលឃុំ សង្កាត់

យន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលឃុំ សង្កាត់គឺជាកន្លែងប្រមូលផ្តុំការផ្តល់សេវារដ្ឋបាលនៅកន្លែងតែមួយ មានលក្ខណៈងាយស្រួល សាមញ្ញ ឆាប់រហ័ស តម្លាភាព គណនេយ្យភាព និងប្រកបដោយភាពជឿជាក់។

យន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលឃុំ សង្កាត់ត្រូវស្ថិតនៅក្រោមការដឹកនាំរបស់មេឃុំ ចៅសង្កាត់ដោយមានស្មៀនឃុំ សង្កាត់ជាសេនាធិការ។

យន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលឃុំ សង្កាត់ត្រូវរៀបចំនៅក្នុងបរិវេណសាលាឃុំ សង្កាត់ ឬទីតាំងណាមួយដែលមានលក្ខណៈសមស្រប និងមានលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋមកទំនាក់ទំនងក្នុងការស្នើសុំសេវារដ្ឋបាល ដោយមានបំពាក់នូវសម្ភារៈចាំបាច់មួយចំនួនសម្រាប់បំពេញការងារដូចខាងក្រោម៖

- រៀបចំទីកន្លែងផ្តល់សេវា ដោយដាក់ផ្លាកសម្គាល់ "**យន្តការច្រកចេញចូលតែមួយ**"
- រៀបចំបញ្ជរ ឬតុសម្រាប់ផ្តល់ព័ត៌មាននិងទទួលប្រគល់ឯកសារ ដោយដាក់ផ្លាកសម្គាល់ "**ផ្តល់ព័ត៌មាននិងទទួលប្រគល់ឯកសារ**"

- រៀបចំបញ្ជរ ឬតុសម្រាប់ទទួលកម្រៃសេវាពីប្រជាពលរដ្ឋ ដោយដាក់ផ្លាកសម្គាល់ "**បេឡា**"
- រៀបចំ និងបិទបង្ហាញតារាងតម្លៃសេវារដ្ឋបាលនៅទីកន្លែងផ្ដល់សេវា
- រៀបចំឱ្យមានទីកន្លែង និងកៅអីរង់ចាំសម្រាប់ប្រជាពលរដ្ឋដែលមកស្នើសុំ និងទទួលសេវា
- បិទបង្ហាញលេខទូរស័ព្ទរបស់អ្នកទទួលខុសត្រូវឱ្យបានច្បាស់លាស់នៅទីកន្លែងផ្ដល់សេវាដែលប្រជាពលរដ្ឋអាចទំនាក់ទំនងបាន ក្នុងករណីចាំបាច់។

គំរូផ្លាកសម្គាល់នានាមានកំណត់នៅក្នុងឧបសម្ព័ន្ធទី១ នៃសេចក្ដីណែនាំនេះ។

## ២. តួនាទី ភារកិច្ច និងការរៀបចំបុគ្គលិក

យន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលឃុំ សង្កាត់ត្រូវបានរៀបចំឡើងសម្រាប់ប្រមូលផ្ដុំការផ្ដល់សេវារដ្ឋបាលទាំងអស់ដែលស្ថិតក្នុងសមត្ថកិច្ចពិនិត្យ និងសម្រេចរបស់រដ្ឋបាលឃុំ សង្កាត់ ដូចបានកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

យន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលឃុំ សង្កាត់អាចទទួលសំណុំឯកសារស្នើសុំសេវា និងផ្ដល់លទ្ធផលសម្រេចជូនអ្នកស្នើសុំសេវា ចំពោះប្រភេទសេវារដ្ឋបាលផ្សេងទៀតដែលមិនស្ថិតនៅក្នុងសមត្ថកិច្ចពិនិត្យ សម្រេចរបស់រដ្ឋបាលឃុំ សង្កាត់ អាស្រ័យទៅតាមការកំណត់របស់រាជរដ្ឋាភិបាល ឬលិខិតបទដ្ឋានរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

### ២.១. តួនាទី ភារកិច្ចរបស់យន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលឃុំ សង្កាត់

យន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលឃុំ សង្កាត់មានតួនាទី ភារកិច្ចដូចខាងក្រោម៖

- ទទួលពាក្យស្នើសុំ ទម្រង់បែបបទ និងសំណុំឯកសារភ្ជាប់ស្នើសុំសេវារដ្ឋបាលរបស់ប្រជាពលរដ្ឋ
- ពិនិត្យ សម្រេចលើរាល់ការស្នើសុំសេវារដ្ឋបាលដែលស្ថិតក្នុងសមត្ថកិច្ចពិនិត្យ និងសម្រេចរបស់រដ្ឋបាលឃុំ សង្កាត់
- បញ្ជូនសំណុំឯកសារស្នើសុំសេវាទៅក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ ដើម្បីពិនិត្យ និងសម្រេចចំពោះប្រភេទសេវារដ្ឋបាលផ្សេងទៀតដែលមិនស្ថិតនៅក្នុងសមត្ថកិច្ចពិនិត្យ សម្រេចរបស់រដ្ឋបាលឃុំ សង្កាត់
- ផ្សព្វផ្សាយ និងផ្ដល់ព័ត៌មាននានាពាក់ព័ន្ធនឹងការផ្ដល់សេវារដ្ឋបាលនៃរដ្ឋបាលឃុំ សង្កាត់ឱ្យបានទូលំទូលាយ
- សម្របសម្រួលដោះស្រាយបញ្ហា និងផ្ដល់ព័ត៌មានជូនប្រជាពលរដ្ឋ ដែលបានដាក់ពាក្យស្នើសុំសេវារដ្ឋបាលនៅយន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលឃុំ សង្កាត់។

**២.២. ការរៀបចំបុគ្គលិក**

មេឃុំ ចៅសង្កាត់ត្រូវរៀបចំ និងចាត់តាំងបុគ្គលិកបំពេញការងារប្រចាំការនៅយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលស្របតាមស្ថានភាពជាក់ស្តែង និងទំហំការងារនៃរដ្ឋបាលឃុំ សង្កាត់នីមួយៗ។

យន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលឃុំ សង្កាត់ត្រូវមានបុគ្គលិកទទួលបន្ទុកការងារ "**ផ្តល់ព័ត៌មាននិងទទួលប្រគល់ឯកសារ**" និងបុគ្គលិកទទួលបន្ទុកការងារ"**បេឡា**"។

ចំពោះការងារ "**ផ្តល់ព័ត៌មាននិងទទួលប្រគល់ឯកសារ**" មេឃុំ ចៅសង្កាត់អាចចាត់តាំងបុគ្គលិកជំនួយការរដ្ឋបាលឃុំ សង្កាត់ ឬបុគ្គលិកស្ម័គ្រចិត្ត ឬស្មៀនឃុំ សង្កាត់(ក្នុងករណីគ្មានជំនួយការរដ្ឋបាល) ឱ្យទទួលបន្ទុកការងារនេះ។ ទន្ទឹមនេះ មេឃុំ ចៅសង្កាត់ក៏អាចប្រើប្រាស់បុគ្គលិកដែលទទួលបានការចាត់តាំងពីក្រសួង ស្ថាប័ន ឬអង្គភាពពាក់ព័ន្ធឱ្យទទួលបន្ទុកការងារ "**ផ្តល់ព័ត៌មាននិងទទួលប្រគល់ឯកសារ**" ផងដែរចំពោះប្រភេទសេវាដែលមិនស្ថិតនៅក្នុងសមត្ថកិច្ចពិនិត្យ សម្រេចរបស់ខ្លួន។

ដោយឡែកការងារ "**បេឡា**" មេឃុំ ចៅសង្កាត់ត្រូវចាត់តាំងជំនួយការហិរញ្ញវត្ថុរដ្ឋបាលឃុំ សង្កាត់ឱ្យទទួលបន្ទុកការងារនេះ។ ក្នុងករណីរដ្ឋបាលឃុំ សង្កាត់មិនទាន់មានជំនួយការហិរញ្ញវត្ថុ មេឃុំ ចៅសង្កាត់ត្រូវចាត់តាំងស្មៀនឃុំ សង្កាត់ឱ្យបំពេញការងារ "**បេឡា**" នេះ ជាបណ្តោះអាសន្នសិន។

ការចាត់តាំង ឬការប្រគល់ភារកិច្ចជូនបុគ្គលិកបំពេញការងារក្នុងយន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលឃុំ សង្កាត់ត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់រដ្ឋបាលឃុំ សង្កាត់។

**បុគ្គលិកទទួលបន្ទុកការងារផ្តល់ព័ត៌មាននិងទទួលប្រគល់ឯកសារមានភារកិច្ចដូចខាងក្រោម៖**

- ផ្តល់ព័ត៌មានទូទៅពាក់ព័ន្ធនឹងការស្នើសុំសេវារដ្ឋបាល ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់យន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលឃុំ សង្កាត់ ដូចជា ប្រភេទសេវា តម្លៃសេវា រយៈពេលនៃការផ្តល់សេវា សុពលភាពនៃសេវា និងបែបបទនីតិវិធីនៃការស្នើសុំសេវា
- ផ្តល់ពាក្យស្នើសុំ និងពន្យល់អំពីតម្រូវការឯកសារភ្ជាប់នៃការស្នើសុំសេវារបស់រដ្ឋបាលឃុំ សង្កាត់
- ជួយណែនាំ ឬជួយបំពេញពាក្យស្នើសុំសេវា ក្នុងករណីអ្នកស្នើសុំសេវាមិនចេះអក្សរ ឬមានពិការភាពមិនអាចបំពេញព័ត៌មានក្នុងពាក្យស្នើសុំដោយខ្លួនឯងបាន
- ទទួល និងពិនិត្យពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់ស្នើសុំសេវារដ្ឋបាលពីអ្នកស្នើសុំសេវា
- ចេញបង្កាន់ដៃទទួលពាក្យស្នើសុំជូនប្រជាពលរដ្ឋ
- ផ្តល់លទ្ធផលសម្រេចជាផ្លូវការនៃសេវារដ្ឋបាលដែលបានស្នើសុំជូនអ្នកស្នើសុំសេវា
- រៀបចំរបាយការណ៍អំពីចំនួនសេវាតាមគោលការណ៍កំណត់
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់មេឃុំ ចៅសង្កាត់។

បុគ្គលិកទទួលបន្ទុកការងារបេឡាមានភារកិច្ចដូចខាងក្រោម៖

- ទទួលកម្រៃសេវារដ្ឋបាលពីប្រជាពលរដ្ឋ និងចេញបង្កាន់ដៃបង់ប្រាក់តាមគោលការណ៍កំណត់
- បញ្ជូនពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់ជូនមេឃុំ ចៅសង្កាត់ពិនិត្យ សម្រេចចំពោះប្រភេទសេវាដែលស្ថិតក្នុងសមត្ថកិច្ចពិនិត្យ សម្រេចរបស់រដ្ឋបាលឃុំ សង្កាត់
- រៀបចំបញ្ជូនសំណុំឯកសារស្នើសុំសេវាទៅក្រសួង ស្ថាប័ន ឬអង្គភាពពាក់ព័ន្ធ ដើម្បីពិនិត្យ សម្រេចចំពោះប្រភេទសេវាដែលមិនស្ថិតក្នុងសមត្ថកិច្ចពិនិត្យ សម្រេចរបស់រដ្ឋបាលឃុំ សង្កាត់ លើកលែងតែមានការកំណត់ផ្សេងពីនេះ
- ទុកដាក់ ថែរក្សា ធានាសុវត្ថិភាពសាច់ប្រាក់ និងបង់ចំណូលដែលទទួលបានពីការផ្តល់សេវាស្របតាមគោលការណ៍ និងនីតិវិធីជាធរមាន
- ទុកដាក់ និងថែរក្សាបង្កាន់ដៃបង់ប្រាក់ស្របតាមគោលការណ៍ និងនីតិវិធីដែលបានកំណត់
- រៀបចំរបាយការណ៍ចំណូលនៃការផ្តល់សេវាតាមគោលការណ៍កំណត់
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់មេឃុំ ចៅសង្កាត់។

## ៣. នីតិវិធីនៃការផ្តល់សេវា

ការផ្តល់សេវារដ្ឋបាលរបស់យន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលឃុំ សង្កាត់ត្រូវអនុវត្តតាមជំហានដូចខាងក្រោម៖

១. ការផ្តល់ព័ត៌មាន និងទម្រង់បែបបទស្នើសុំសេវា

២. ការទទួលទម្រង់បែបបទស្នើសុំសេវារដ្ឋបាល និងសំណុំឯកសារភ្ជាប់

៣. ការបង់កម្រៃសេវារដ្ឋបាល

៤. ការពិនិត្យ សម្រេច និងការផ្តល់លទ្ធផលសម្រេច។

### ៣.១. ការផ្តល់ព័ត៌មាន និងទម្រង់បែបបទស្នើសុំសេវា

នៅពេលប្រជាពលរដ្ឋមកទំនាក់ទំនងសាកសួរព័ត៌មានផ្សេងៗ ដែលពាក់ព័ន្ធនឹងការផ្តល់សេវារដ្ឋបាលនៅបញ្ជរ ឬតុផ្តល់ព័ត៌មាននិងទទួលប្រគល់ឯកសាររបស់យន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលឃុំ សង្កាត់ បុគ្គលិកទទួលបន្ទុកការងារផ្តល់ព័ត៌មាននិងទទួលប្រគល់ឯកសារត្រូវផ្តល់ព័ត៌មានសំខាន់ៗជូនប្រជាពលរដ្ឋលើប្រភេទសេវាដែលចង់ស្នើសុំ រួមមាន តម្លៃសេវា រយៈពេលនៃការផ្តល់សេវា សុពលភាពនៃសេវា ទម្រង់បែបបទ និងឯកសារភ្ជាប់នានាជាដើម។ បុគ្គលិកទទួលបន្ទុកត្រូវផ្តល់ព័ត៌មានដែលត្រឹមត្រូវច្បាស់លាស់ សាមញ្ញ និងងាយយល់ ប្រកបដោយភាពរួសរាយ ទន់ភ្លន់ និងពាក្យសម្តីសមរម្យ។

ក្នុងករណីប្រជាពលរដ្ឋមានបំណងស្នើសុំសេវារដ្ឋបាលណាមួយដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់យន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលឃុំ សង្កាត់ បុគ្គលិកទទួលបន្ទុកការងារផ្តល់ព័ត៌មាននិងទទួលប្រគល់ឯកសារត្រូវផ្តល់ជូនប្រជាពលរដ្ឋនូវទម្រង់បែបបទស្នើសុំសេវារដ្ឋបាលដើម្បីបំពេញព័ត៌មាន។ បុគ្គលិក

ទទួលបន្ទុកត្រូវពន្យល់ដល់ប្រជាពលរដ្ឋអំពីរបៀបនៃការបំពេញព័ត៌មានក្នុងទម្រង់បែបបទស្នើសុំសេវារដ្ឋបាល និងតម្រូវការឯកសារភ្ជាប់ទាំងអស់ក្នុងពេលតែ១លើក ជៀសវាងបង្កការលំបាកដល់ប្រជាពលរដ្ឋ។

ការផ្តល់ទម្រង់បែបបទនៃការស្នើសុំសេវារដ្ឋបាលមិនតម្រូវឱ្យប្រជាពលរដ្ឋបង់ថ្លៃសេវាឡើយ លើកលែងតែមានការកំណត់ក្នុងលិខិតបទដ្ឋានផ្សេងពីនេះ។ ចំពោះអ្នកស្នើសុំសេវាដែលមិនចេះអក្សរ ឬមានពិការភាពមិនអាចបំពេញព័ត៌មានលើទម្រង់បែបបទស្នើសុំសេវាបានដោយខ្លួនឯង បុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មាន និងទទួលប្រគល់ឯកសារត្រូវជួយបំពេញព័ត៌មានជូនប្រជាពលរដ្ឋដោយមិនគិតកម្រៃសេវាឡើយ។

**៣.២. ការទទួលទម្រង់បែបបទស្នើសុំសេវារដ្ឋបាល និងសំណុំឯកសារភ្ជាប់**

ការទទួលទម្រង់បែបបទស្នើសុំសេវារដ្ឋបាល និងសំណុំឯកសារភ្ជាប់ត្រូវធ្វើឡើងនៅបញ្ជរ ឬតុផ្តល់ព័ត៌មាន និងទទួលប្រគល់ឯកសាររបស់យន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលឃុំ សង្កាត់។

ក្នុងការទទួលទម្រង់បែបបទស្នើសុំសេវារដ្ឋបាល និងសំណុំឯកសារភ្ជាប់ពីអ្នកស្នើសុំសេវា បុគ្គលិកទទួលបន្ទុកការងារផ្តល់ព័ត៌មាន និងទទួលប្រគល់ឯកសារត្រូវផ្តោតការយកចិត្តទុកដាក់ដូចខាងក្រោម៖

១) ពិនិត្យទៅលើភាពពេញលេញ ត្រឹមត្រូវ ច្បាស់លាស់នៃព័ត៌មានដែលបានបំពេញក្នុងទម្រង់បែបបទស្នើសុំសេវារដ្ឋបាល។ ក្នុងករណីដែលការបំពេញព័ត៌មានពុំមានលក្ខណៈពេញលេញ ឬពុំទាន់ត្រឹមត្រូវ បុគ្គលិកទទួលបន្ទុកត្រូវជម្រាបជូន ឬផ្តល់ព័ត៌មានដល់អ្នកស្នើសុំសេវាឱ្យបំពេញបន្ថែមនូវចំណុចដែលខ្វះខាត ឬកែតម្រូវព័ត៌មានដែលបំពេញមិនទាន់បានត្រឹមត្រូវឡើងវិញ។ ចំពោះការបំពេញបន្ថែម ឬការកែតម្រូវព័ត៌មានដែលមានលក្ខណៈតិចតួច អាចធ្វើឡើងភ្លាមៗនៅបញ្ជរ ឬតុផ្តល់ព័ត៌មាននិងទទួលប្រគល់ឯកសារតែម្តង។

២) ពិនិត្យទៅលើភាពគ្រប់គ្រាន់ និងភាពត្រឹមត្រូវនៃសំណុំឯកសារភ្ជាប់ ស្របតាមលក្ខខណ្ឌកំណត់ទៅតាមប្រភេទសេវារដ្ឋបាលនីមួយៗ។ ក្នុងករណីដែលសំណុំឯកសារភ្ជាប់ពុំទាន់មានភាពត្រឹមត្រូវ ឬគ្រប់គ្រាន់តាមលក្ខខណ្ឌកំណត់ បុគ្គលិកទទួលបន្ទុកត្រូវជម្រាបជូនអ្នកស្នើសុំសេវាឱ្យរៀបចំឯកសារភ្ជាប់ឱ្យបានត្រឹមត្រូវ និងគ្រប់គ្រាន់ទៅតាមប្រភេទសេវារដ្ឋបាលនីមួយៗដែលបានស្នើសុំ។

បុគ្គលិកទទួលបន្ទុកការងារផ្តល់ព័ត៌មាននិងទទួលប្រគល់ឯកសារ មិនត្រូវទាមទារឯកសារភ្ជាប់បន្ថែមពីអ្នកស្នើសុំសេវាលើសពីលក្ខខណ្ឌកំណត់ដោយលិខិតបទដ្ឋានដែលនៅជាធរមានឡើយ។

នៅពេលពិនិត្យឃើញថា សំណុំឯកសារស្នើសុំសេវារដ្ឋបាលមានលក្ខណៈពេញលេញ និងត្រឹមត្រូវស្របតាមគោលការណ៍ និងលក្ខខណ្ឌកំណត់ បុគ្គលិកទទួលបន្ទុកការងារផ្តល់ព័ត៌មាននិងទទួលប្រគល់ឯកសារ ត្រូវកត់ត្រាការស្នើសុំសេវារដ្ឋបាលដូចខាងក្រោម៖

- បោះត្រាចូលលើពាក្យស្នើសុំ ចុះលេខ និងចុះកាលបរិច្ឆេទ *(ឧបសម្ព័ន្ធទី២)*
- ចុះក្នុងសៀវភៅកត់ត្រាលិខិតចូល ឬប្រើប្រាស់ប្រព័ន្ធកត់ត្រាទិន្នន័យ *(ប្រសិនបើមាន)*
- ចេញ**បង្កាន់ដៃទទួលពាក្យ** *(ឧបសម្ព័ន្ធទី៣)*

- បញ្ជូនសំណុំឯកសារស្នើសុំសេវាទៅបញ្ជរ ឬតុបេឡា
- អញ្ជើញអ្នកស្នើសុំសេវាឱ្យទៅបង់កម្រៃសេវានៅបញ្ជរ ឬតុបេឡារបស់យន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលឃុំ សង្កាត់ ក្នុងករណីដែលសេវានោះតម្រូវឱ្យមានការបង់កម្រៃសេវា។

### ៣.៣. ការបង់កម្រៃសេវារដ្ឋបាល

ការបង់កម្រៃសេវារដ្ឋបាលត្រូវធ្វើឡើងនៅបញ្ជរ ឬតុបេឡារបស់យន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលឃុំ សង្កាត់ លើកលែងតែមានការកំណត់ផ្សេងពីនេះ។

បុគ្គលិកទទួលបន្ទុកការងារបេឡាត្រូវពិនិត្យលើបង្កាន់ដៃទទួលពាក្យរបស់អ្នកស្នើសុំសេវា ដើម្បីចេញបង្កាន់ដៃបង់ប្រាក់ជូនអ្នកស្នើសុំសេវា ផ្អែកទៅតាមប្រភេទសេវារដ្ឋបាល និងតម្លៃសេវាដែលបានកំណត់។ បុគ្គលិកទទួលបន្ទុកការងារបេឡាត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើកលែងតែមានការកំណត់ផ្សេងពីនេះ។ ចំណូលដែលបានមកពីការផ្តល់សេវារដ្ឋបាលរបស់យន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលឃុំ សង្កាត់ ត្រូវគ្រប់គ្រងដោយជំនួយការហិរញ្ញវត្ថុរដ្ឋបាលឃុំ សង្កាត់ ឬស្មៀនឃុំ សង្កាត់ (ក្នុងករណីមិនទាន់មានជំនួយការហិរញ្ញវត្ថុ) ស្របតាមគោលការណ៍ និងនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលឃុំ សង្កាត់។

រាល់ការទាមទារកម្រៃសេវាបន្ថែមពីអ្នកស្នើសុំសេវា លើសពីការកំណត់នៅក្នុងតារាងតម្លៃសេវារដ្ឋបាលរបស់រដ្ឋបាលឃុំ សង្កាត់ ក្រោមហេតុផលផ្សេងៗ ត្រូវចាត់ទុកជាអំពើខុសច្បាប់។

ក្រោយពេលបានចេញបង្កាន់ដៃបង់ប្រាក់ជូនអ្នកស្នើសុំសេវា បុគ្គលិកទទួលបន្ទុកការងារបេឡាត្រូវបញ្ជូនទម្រង់បែបបទ និងសំណុំឯកសារភ្ជាប់ភ្លាមៗជូនមេឃុំ ចៅសង្កាត់ ដើម្បីពិនិត្យ និងសម្រេច។

ចំពោះប្រភេទសេវារដ្ឋបាលផ្សេងទៀតដែលមិនស្ថិតក្នុងសមត្ថកិច្ចពិនិត្យ សម្រេចរបស់រដ្ឋបាលឃុំ សង្កាត់ បុគ្គលិកទទួលបន្ទុកការងារបេឡាត្រូវរៀបចំប្រគល់សំណុំឯកសារស្នើសុំសេវាទាំងនោះជូនបុគ្គលិកដែលទទួលបានការចាត់តាំងពីក្រសួង ស្ថាប័ន ឬអង្គភាពពាក់ព័ន្ធ ដើម្បីចាត់ចែងអនុវត្តតាមការកំណត់របស់ក្រសួង ស្ថាប័ន ឬអង្គភាពពាក់ព័ន្ធ ដោយប្រើប្រាស់ទម្រង់លិខិតប្រគល់-ទទួលឯកសារ (ឧបសម្ព័ន្ធទី៤)។ ក្នុងករណីក្រសួង ស្ថាប័ន ឬអង្គភាពពាក់ព័ន្ធមិនបានចាត់តាំងបុគ្គលិកឱ្យមកបំពេញការងារនៅយន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលឃុំ សង្កាត់ទេ បុគ្គលិកទទួលបន្ទុកការងារបេឡាត្រូវរៀបចំសេចក្តីព្រាងដីកាអមដោយភ្ជាប់ជាមួយសំណុំឯកសារស្នើសុំសេវា ដើម្បីដាក់ជូនមេឃុំ ចៅសង្កាត់ចុះហត្ថលេខា ហើយត្រូវបញ្ជូនដីកាអម និងសំណុំឯកសារស្នើសុំសេវាទាំងនោះជូនក្រសួង ស្ថាប័ន ឬអង្គភាពពាក់ព័ន្ធមានសមត្ថកិច្ច ដើម្បីពិនិត្យ និងសម្រេច។

### ៣.៤. ការពិនិត្យ សម្រេច និងការផ្តល់លទ្ធផលសម្រេច

មេឃុំ ចៅសង្កាត់គឺជាអ្នកពិនិត្យ និងសម្រេចលើរាល់សំណុំឯកសារស្នើសុំសេវារដ្ឋបាលរបស់អ្នកស្នើសុំសេវានៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ មេឃុំ ចៅសង្កាត់ត្រូវពិនិត្យ និងសម្រេចលើរាល់សំណុំឯកសារស្នើសុំសេវារដ្ឋបាលឱ្យបានឆាប់រហ័ស និងមិនត្រូវឱ្យលើសពីរយៈពេលដែលបានកំណត់ក្នុងលិខិតបទដ្ឋាន

គតិយុត្តជាធរមាន។ ក្នុងការពិនិត្យ សម្រេចលើការស្នើសុំសេវារដ្ឋបាល មេឃុំ ចៅសង្កាត់អាចប្រគល់សិទ្ធិជូនជំទប់ ឬចៅសង្កាត់រងរបស់ខ្លួន ស្របតាមមាត្រា៤០នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដើម្បីពន្លឿនការផ្តល់សេវារដ្ឋបាលជូនអ្នកស្នើសុំសេវា។

ចំពោះប្រភេទសេវារដ្ឋបាលមួយចំនួនដែលតម្រូវឱ្យមានការពិនិត្យ ផ្តល់យោបល់ ឬចុះហត្ថលេខាបញ្ជាក់ពីមេភូមិមុនការពិនិត្យ សម្រេច មេឃុំ ចៅសង្កាត់ត្រូវចាត់ចែងឱ្យមេភូមិមកពិនិត្យ ផ្តល់យោបល់ ឬចុះហត្ថលេខាបញ្ជាក់លើឯកសារទាំងនោះនៅសាលាឃុំ សង្កាត់ឱ្យបានឆាប់រហ័ស ដោយមិនត្រូវឱ្យអ្នកស្នើសុំសេវាយកឯកសារស្នើសុំសេវាទៅពិនិត្យបញ្ជាក់ពីមេភូមិឡើយ។

បន្ទាប់ពីបានពិនិត្យ សម្រេច និងចុះហត្ថលេខាដោយមេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ព្រមទាំងបោះត្រា ចុះលេខលើលិខិតរួច លទ្ធផលសម្រេចនៃការស្នើសុំសេវារដ្ឋបាលទាំងនោះត្រូវបញ្ជូនទៅបុគ្គលិកទទួលបន្ទុកការងារផ្តល់ព័ត៌មាននិងទទួលប្រគល់ឯកសារ ដើម្បីប្រគល់ជូនអ្នកស្នើសុំសេវា។

ក្នុងករណីដែលរដ្ឋបាលឃុំ សង្កាត់ពិនិត្យឃើញថា មិនអាចសម្រេចផ្តល់សេវាណាមួយជូនអ្នកស្នើសុំសេវាបាន មេឃុំ ចៅសង្កាត់ត្រូវចាត់ចែងផ្តល់ព័ត៌មានត្រឡប់ជូនអ្នកស្នើសុំសេវាវិញឱ្យបានច្បាស់លាស់អំពីមូលហេតុដែលរដ្ឋបាលឃុំ សង្កាត់មិនអាចផ្តល់សេវាតាមការស្នើសុំ។

ចំពោះប្រភេទសេវារដ្ឋបាលដែលមិនស្ថិតក្នុងសមត្ថកិច្ចពិនិត្យ សម្រេចរបស់រដ្ឋបាលឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ត្រូវសម្របសម្រួល ជំរុញ និងតាមដានលើការផ្តល់សេវាដោយក្រសួង ស្ថាប័ន ឬអង្គភាពពាក់ព័ន្ធនឹងការស្នើសុំសេវាទាំងនោះឱ្យបានឆាប់រហ័ស ស្របតាមពេលវេលាដែលបានកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ក្នុងករណីដែលមានភាពយឺតយ៉ាវក្នុងការផ្តល់សេវារដ្ឋបាលជូនអ្នកស្នើសុំសេវា មេឃុំ ចៅសង្កាត់ត្រូវចាត់ចែងឱ្យបុគ្គលិកទទួលបន្ទុកការងារផ្តល់ព័ត៌មាននិងទទួលប្រគល់ឯកសារជូនដំណឹងដល់អ្នកស្នើសុំសេវារដ្ឋបាល ដោយបញ្ជាក់អំពីមូលហេតុនៃភាពយឺតយ៉ាវនោះ។

## ៤. ទម្រង់បែបបទស្នើសុំសេវារដ្ឋបាល

មេឃុំ ចៅសង្កាត់ត្រូវធានាថា ទម្រង់បែបបទស្នើសុំសេវារដ្ឋបាលមានគ្រប់គ្រាន់នៅក្នុងយន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលឃុំ សង្កាត់របស់ខ្លួនសម្រាប់ផ្តល់ជូនប្រជាពលរដ្ឋ។ គំរូទម្រង់បែបបទស្នើសុំសេវារដ្ឋបាលរបស់យន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលឃុំ សង្កាត់មានកំណត់នៅក្នុងឧបសម្ព័ន្ធទី៥ភ្ជាប់នឹងសេចក្តីណែនាំនេះ។

ចំពោះប្រភេទសេវាមួយចំនួនដែលតម្រូវឱ្យមានការបញ្ជាក់ពីរដ្ឋបាលឃុំ សង្កាត់ទៅតាមទម្រង់បែបបទរបស់ក្រសួង ស្ថាប័នជំនាញ រដ្ឋបាលឃុំ សង្កាត់ត្រូវប្រើប្រាស់ទម្រង់ដែលកំណត់ដោយក្រសួង ស្ថាប័នជំនាញនោះសម្រាប់ផ្តល់សេវាជូនប្រជាពលរដ្ឋ។

## ៥. ការគាំទ្រ ការផ្សព្វផ្សាយ និងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

អគ្គនាយកដ្ឋានពាក់ព័ន្ធចំណុះក្រសួងមហាផ្ទៃមានតួនាទីសម្របសម្រួលជាមួយក្រសួង ស្ថាប័ន ឬ អង្គភាពពាក់ព័ន្ធដើម្បីផ្តល់ការគាំទ្រផ្នែកបច្ចេកទេស ការអភិវឌ្ឍសមត្ថភាព និងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការផ្តល់សេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលឃុំ សង្កាត់។

រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវជួយធ្វើការផ្សព្វផ្សាយព័ត៌មានអំពីការផ្តល់សេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលឃុំ សង្កាត់ និងត្រូវផ្តល់ការគាំទ្រ ធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ព្រមទាំងជួយសម្របសម្រួលដោះស្រាយបញ្ហានានាពាក់ព័ន្ធនឹងការផ្តល់សេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលឃុំ សង្កាត់។

រដ្ឋបាលឃុំ សង្កាត់ត្រូវធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋអំពីយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលឃុំ សង្កាត់ តាមគ្រប់មធ្យោបាយដែលមាននៅក្នុងមូលដ្ឋានរបស់ខ្លួនដូចជា ក្តារព័ត៌មាន វេទិកាសាធារណៈ កិច្ចប្រជុំ និងបណ្តាញសង្គមនានាជាដើម។

រដ្ឋបាលឃុំ សង្កាត់ត្រូវបិទផ្សាយតារាងតម្លៃសេវារដ្ឋបាលរបស់យន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលឃុំ សង្កាត់របស់ខ្លួនតាមទីប្រជុំជន និងនៅតាមទីសាធារណៈនានាក្នុងមូលដ្ឋានរបស់ខ្លួន។

រដ្ឋបាលឃុំ សង្កាត់ត្រូវរៀបចំឱ្យមានការផ្តល់ព័ត៌មានត្រឡប់តាមរយៈមធ្យោបាយផ្សេងៗ អំពីការផ្តល់សេវារដ្ឋបាលរបស់យន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលឃុំ សង្កាត់ ដើម្បីទទួលបានព័ត៌មានពីប្រជាពលរដ្ឋអំពីភាពពេញចិត្ត ឬចំណុចខ្វះខាត ឬសំណូមពរនានាពាក់ព័ន្ធនឹងការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលឃុំ សង្កាត់។

មេឃុំ ចៅសង្កាត់ ត្រូវសម្របសម្រួលដោះស្រាយនូវបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងការផ្តល់សេវារដ្ឋបាលក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ក្នុងករណីដែលមិនអាចដោះស្រាយបញ្ហាប្រឈមនានាពាក់ព័ន្ធការផ្តល់សេវារដ្ឋបាលក្នុងដែនសមត្ថកិច្ចរបស់ខ្លួន មេឃុំ ចៅសង្កាត់ត្រូវលើកសំណើ ឬសំណូមពរមករដ្ឋបាលក្រុង ស្រុក ខណ្ឌ ឬរដ្ឋបាលរាជធានី ខេត្ត ឬក្រសួងមហាផ្ទៃ ដើម្បីជួយសម្របសម្រួល និងផ្តល់ការគាំទ្រក្នុងការដោះស្រាយបញ្ហាប្រឈមទាំងនោះ។

រដ្ឋបាលឃុំ សង្កាត់ត្រូវធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃជាទៀងទាត់ទៅលើកិច្ចដំណើរការនៃការផ្តល់សេវារដ្ឋបាលនៅយន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលឃុំ សង្កាត់របស់ខ្លួន និងរៀបចំរបាយការណ៍ជាទៀងទាត់ស្របតាមគោលការណ៍កំណត់។

## ៦. ការសម្រុះសម្រួលដោះស្រាយបណ្តឹង

ក្នុងករណីប្រជាពលរដ្ឋមានការមិនពេញចិត្តពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈ និងការគ្រប់គ្រងរដ្ឋបាលនៅរដ្ឋបាលឃុំ សង្កាត់ ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិដាក់ពាក្យបណ្តឹង ឬផ្តល់ព័ត៌មានផ្សេងៗទៅការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌមានសមត្ថកិច្ច តាមរយៈការអញ្ជើញទៅផ្ទាល់ដល់ទីកន្លែង

បំពេញការងាររបស់ការិយាល័យប្រជាពលរដ្ឋ ឬតាមប្រព័ន្ធទូរស័ព្ទ ឬតាមប្រអប់សំបុត្ររបស់ការិយាល័យប្រជាពលរដ្ឋ ឬតាមប្រព័ន្ធអេឡិចត្រូនិច ដោយពុំមានបង់ថ្លៃសេវាឡើយ។

ទទួលបានសេចក្តីណែនាំនេះ គ្រប់អង្គភាពពាក់ព័ន្ធចំណុះក្រសួងមហាផ្ទៃ រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ត្រូវចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាព និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃ...សុក្រ ១៣កើត....ខែពិសាខ....ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...១៣....ខែ..ឧសភា.. ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**<u>កន្លែងទទួល</u>** ÷

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- អង្គភាពប្រឆាំងអំពើពុករលួយ
- លេខាធិការដ្ឋាន គ.ជ.អ.ប.
- ឯកសារ-កាលប្បវត្តិ

# យន្តការច្រកចេញចូលតែមួយ

# ONE WINDOW SERVICE MECHANISM

**កន្លែងរង់ចាំ**
Waiting Area

**បេឡា**
Cashier

**ផ្តល់ព័ត៌មាននិងទទួលប្រគល់ឯកសារ**
Information and Application Submission

**លេខទូរស័ព្ទសម្រាប់សាកសួរព័ត៌មាន**

**មេឃុំ/ចៅសង្កាត់ ៖**

**ស្មៀនឃុំ/សង្កាត់ ៖**

**ការបង់កម្រៃសេវា ឬការទាមទារឱ្យបង់កម្រៃសេវាលើសការកំណត់គឺជាអំពើខុសច្បាប់**

ក្នុងករណីមានការទាមទារឱ្យបង់កម្រៃសេវាលើសពីការកំណត់សូមធ្វើការទំនាក់ទំនង

មកការិយាល័យប្រជាពលរដ្ឋតាមរយៈទូរស័ព្ទលេខ៖

(ឈ្មោះប្រធានការិយាល័យប្រជាពលរដ្ឋ) ៖ (លេខទូរស័ព្ទ)៖

អាសយដ្ឋានតាមប្រព័ន្ធអេឡិចត្រូនិច(ប្រសិនបើមាន)៖

## ពេលវេលាបំពេញការងារ

## ថ្ងៃ..... ដល់ថ្ងៃ.....

ព្រឹក ៖ ....... - .......

រសៀល ៖ ....... - .......

Working Hours

From....... to .......

.......AM - .......AM

.......PM - .......PM

<u>សម្គាល់៖</u> ដើម្បីជានាដល់ប្រសិទ្ធភាពនៃការផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋ រដ្ឋបាលឃុំ សង្កាត់នីមួយៗអាចកំណត់ថ្ងៃធ្វើការ និងពេលវេលាបំពេញការងារជាក់ស្តែងរបស់យន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលឃុំ សង្កាត់ ស្របតាមស្ថានភាព និងតម្រូវការស្នើសុំសេវារបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន។

ឧបសម្ព័ន្ធទី២៖ គំរូត្រាលិខិតចូល

<table>
<tr><td colspan="2">រដ្ឋបាលឃុំ/សង្កាត់...................<br>យន្តការច្រកចេញចូលតែមួយ</td></tr>
<tr><td>ចូល</td><td>លេខ.........................................................<br>ថ្ងៃទី.................ខែ...............ឆ្នាំ២០............<br>ម៉ោង.........................................................</td></tr>
</table>

**ឧបសម្ព័ន្ធទី៣ ÷ បង្កាន់ដៃទទួលពាក្យ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជធានី ខេត្ត**....................................

**ក្រុង ស្រុក ខណ្ឌ**................................

**រដ្ឋបាលឃុំ សង្កាត់**.............................. **លេខបង្កាន់ដៃ**.........................

## បង្កាន់ដៃទទួលពាក្យស្នើសុំសេវារដ្ឋបាល

យន្តការច្រកចេញចូលតែមួយ

បានទទួលពាក្យស្នើសុំពីឈ្មោះ៖.............................................................

អាសយដ្ឋាន៖.............................................................................

លេខទូរស័ព្ទ៖.............................................................................

កម្មវត្ថុស្នើសុំសេវា៖......................................................................

កាលបរិច្ឆេទទទួលពាក្យស្នើសុំ៖.................................ម៉ោង...............

កាលបរិច្ឆេទមកទទួលលទ្ធផលសម្រេច ៖..................................................

**បុគ្គលិកទទួលបន្ទុកការងារ**

**ផ្តល់ព័ត៌មាននិងទទួលប្រគល់ឯកសារ**

លេខទូរស័ព្ទសម្រាប់សាកសួរព័ត៌មាន៖

..........................................................................

លេខទូរស័ព្ទសម្រាប់ការប្តឹងតវ៉ានានា៖


**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជធានី ខេត្ត**....................................

**ក្រុង ស្រុក ខណ្ឌ**................................

**រដ្ឋបាលឃុំ សង្កាត់**.............................. **លេខបង្កាន់ដៃ**.........................

## បង្កាន់ដៃទទួលពាក្យស្នើសុំសេវារដ្ឋបាល

យន្តការច្រកចេញចូលតែមួយ

បានទទួលពាក្យស្នើសុំពីឈ្មោះ៖.............................................................

អាសយដ្ឋាន៖.............................................................................

លេខទូរស័ព្ទ៖.............................................................................

កម្មវត្ថុស្នើសុំសេវា៖......................................................................

កាលបរិច្ឆេទទទួលពាក្យស្នើសុំ៖.................................ម៉ោង...............

កាលបរិច្ឆេទមកទទួលលទ្ធផលសម្រេច ៖..................................................

**បុគ្គលិកទទួលបន្ទុកការងារ**

**ផ្តល់ព័ត៌មាននិងទទួលប្រគល់ឯកសារ**

លេខទូរស័ព្ទសម្រាប់សាកសួរព័ត៌មាន៖

..........................................................................

លេខទូរស័ព្ទសម្រាប់ការប្តឹងតវ៉ានានា៖

**ឧបសម្ព័ន្ធទី៤÷ លិខិតប្រគល់-ទទួលឯកសារ**

**<u>លិខិតប្រគល់-ទទួលឯកសារ</u>**

( សម្រាប់អ្នកប្រគល់ឯកសារ )

ឈ្មោះ............................................ ជាបុគ្គលិកទទួលបន្ទុកការងារបេឡានៃយន្តការច្រកចេញចូលតែមួយ ឃុំ/សង្កាត់............................................ បានប្រគល់ឯកសារចំនួន......... ច្បាប់ ទៅឱ្យឈ្មោះ........................... ជាបុគ្គលិក.................................... ដែលមានរាយឈ្មោះឯកសារដូចខាងក្រោម៖

១. .....................................................................................................................................

២. .....................................................................................................................................

៣. .....................................................................................................................................

.... ...................................................................................................................................។

ថ្ងៃទី......... ខែ.......... ឆ្នាំ...........

**អ្នកទទួលឯកសារ**
ហត្ថលេខា និងឈ្មោះ

**អ្នកប្រគល់ឯកសារ**
ហត្ថលេខា និងឈ្មោះ

---

**<u>លិខិតប្រគល់-ទទួលឯកសារ</u>**

( សម្រាប់អ្នកទទួលឯកសារ )

ឈ្មោះ............................................ ជាបុគ្គលិកទទួលបន្ទុកការងារបេឡានៃយន្តការច្រកចេញចូលតែមួយ ឃុំ/សង្កាត់............................................ បានប្រគល់ឯកសារចំនួន......... ច្បាប់ ទៅឱ្យឈ្មោះ........................... ជាបុគ្គលិក.................................... ដែលមានរាយឈ្មោះឯកសារដូចខាងក្រោម៖

១. .....................................................................................................................................

២. .....................................................................................................................................

៣. .....................................................................................................................................

.... ...................................................................................................................................។

ថ្ងៃទី......... ខែ.......... ឆ្នាំ...........

**អ្នកទទួលឯកសារ**
ហត្ថលេខា និងឈ្មោះ

**អ្នកប្រគល់ឯកសារ**
ហត្ថលេខា និងឈ្មោះ

**ឧបសម្ព័ន្ធទី៥ ÷ គំរូទម្រង់បែបបទស្នើសុំសេវារដ្ឋបាល**

**៥.១ ÷ គំរូពាក្យស្នើសុំលិខិតបញ្ជាក់**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យស្នើសុំលិខិតបញ្ជាក់របស់រដ្ឋបាលឃុំ/សង្កាត់

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.................................................... ភេទ.......... សញ្ជាតិ.......... ថ្ងៃខែឆ្នាំកំណើត....../....../........ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/លិខិតឆ្លងដែនលេខ...................................................... មុខរបរ................................................ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ/អគារ...................... ផ្លូវលេខ............ ភូមិ........................... ឃុំ/សង្កាត់........................................ ក្រុង/ស្រុក/ខណ្ឌ......................................... រាជធានី/ខេត្ត...............................។

**សូមគោរពជូន**

**លោក លោកស្រីមេឃុំ/ចៅសង្កាត់....................**

**<u>កម្មវត្ថុ</u> ÷** សំណើសុំចេញលិខិតបញ្ជាក់របស់រដ្ឋបាលឃុំ/សង្កាត់។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ/នាងខ្ញុំ សូមជម្រាបជូនលោក លោកស្រីមេឃុំ/ចៅសង្កាត់ មេត្តាជ្រាបថា ខ្ញុំបាទ/នាងខ្ញុំមានបំណងស្នើសុំលិខិតបញ្ជាក់របស់រដ្ឋបាលឃុំ/សង្កាត់ដូចខាងក្រោម៖

| | |
|---|---|
| ☐ លិខិតបញ្ជាក់ភាពនៅលីវ មេម៉ាយ ឬពោះម៉ាយ ចំនួន.......សន្លឹក | ☐ លិខិតបញ្ជាក់ប្រវត្តិរូបសង្ខេប ចំនួន.......សន្លឹក |
| ☐ លិខិតបញ្ជាក់ទីលំនៅ ចំនួន.......សន្លឹក | ☐ លិខិតបញ្ជាក់ទិញលក់សត្វពាហនៈ ចំនួន.......សន្លឹក |
| ☐ លិខិតបញ្ជាក់លើកិច្ចសន្យាខ្ចីប្រាក់ ចំនួន.......សន្លឹក | ☐ លិខិតបញ្ជាក់តបណ្តាញអគ្គិសនី ចំនួន.......សន្លឹក |
| ☐ លិខិតបញ្ជាក់ពីប្រវត្តិដីធ្លី ចំនួន.......ច្បាប់ | ☐ លិខិតបញ្ជាក់តបណ្តាញទឹកស្អាត ចំនួន.......សន្លឹក |
| ☐ លិខិតបញ្ជាក់ទាយាទ ចំនួន.......សន្លឹក | ☐ លិខិតបញ្ជាក់ជួលដី ផ្ទះ តូប យានជំនិះ ចំនួន.......ច្បាប់ |
| ☐ លិខិតបញ្ជាក់កិរិយាមាយាទ ចំនួន.......សន្លឹក | ☐ លិខិតបញ្ជាក់ផ្ទះជួលបន្ទប់ស្នាក់នៅ ចំនួន.......សន្លឹក |
| ☐ លិខិតបញ្ជាក់លើលិខិតស្នាមផ្សេងៗទៀត (ដែលមិនមែនជាសមត្ថកិច្ចរបស់ស្ថាប័នណាមួយ).......................................................................................................................................................................ចំនួន..........សន្លឹក/ច្បាប់។ | |

អាស្រ័យហេតុនេះ សូមលោក លោកស្រីមេឃុំ/ចៅសង្កាត់ មេត្តាចេញលិខិតបញ្ជាក់ជូនខ្ញុំបាទ/នាងខ្ញុំ ដើម្បីយកទៅប្រើប្រាស់តាមការចាំបាច់ដោយក្តីអនុគ្រោះ។

សូមលោក លោកស្រីមេឃុំ/ចៅសង្កាត់ មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

សូមលោក លោកស្រី ទទួលនូវសេចក្តីគោរព រាប់អានអំពីខ្ញុំ។

................. ថ្ងៃទី........ខែ................ឆ្នាំ ២០.....

**ស្នាមមេដៃ/ហត្ថលេខា និងឈ្មោះអ្នកស្នើសុំ**

**ឯកសារភ្ជាប់សម្រាប់ស្នើសុំលិខិតបញ្ជាក់របស់រដ្ឋបាលឃុំ/សង្កាត់**

| ល.រ | ប្រភេទសេវា | តម្រូវការឯកសារភ្ជាប់ | |
|---|---|---|---|
| ១ | **លិខិតបញ្ជាក់ភាពនៅលីវ មេម៉ាយ ឬពោះម៉ាយ** | ☐ ១. **សម្រាប់ប្រជាពលរដ្ឋដែលនៅលីវ៖** អត្តសញ្ញាណប័ណ្ណ និង លិខិតបញ្ជាក់របស់សាក្សី (មេភូមិ ឬចាស់ទុំនៅក្នុងភូមិ) **សម្រាប់ប្រជាពលរដ្ឋដែលនៅមេម៉ាយ ឬពោះម៉ាយ៖** សេចក្តីចម្លងលិខិតមរណភាពអតីតប្តី-ប្រពន្ធ ឬសាលក្រម ឬសាលដីកា ឬដីកាសម្រេចស្ថាពររបស់តុលាការ | ១ច្បាប់ |
| | | ☐ ២. រូបថត ៤x៦ | ១សន្លឹក |
| ២ | **លិខិតបញ្ជាក់ទីលំនៅ** | ☐ ១. អត្តសញ្ញាណប័ណ្ណ ឬសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ឬលិខិតឆ្លងដែន (ថតចម្លង) | ១សន្លឹក |
| | | ☐ ២. កិច្ចសន្យាទិញ-លក់ ឬជួលផ្ទះ (ថតចម្លង) | ១ច្បាប់ |
| | | ☐ ៣. រូបថត ៤x៦ | ១សន្លឹក |
| ៣ | **លិខិតបញ្ជាក់លើកិច្ចសន្យាខ្ចីប្រាក់** | ☐ ១. អត្តសញ្ញាណប័ណ្ណ(ថតចម្លង)(ភាគីទាំងពីរ) | ១សន្លឹក |
| | | ☐ ២. កិច្ចសន្យាខ្ចីប្រាក់ | ១ច្បាប់ |
| | | ☐ ៣. ឯកសារបញ្ជាក់កម្មសិទ្ធិលើវត្ថុធានាកិច្ចសន្យាខ្ចីប្រាក់ | ១ច្បាប់ |
| ៤ | **លិខិតបញ្ជាក់ប្រវត្តិដីធ្លី** | ☐ ឯកសារពាក់ព័ន្ធនឹងការកាន់កាប់អាស្រ័យផល(ថតចម្លង) | ១ច្បាប់ |
| ៥ | **លិខិតបញ្ជាក់ទាយាទ** | ☐ ១.សំបុត្រមរណភាពឪពុក ឬម្តាយនៃទាយាទ | ១សន្លឹក |
| | | ☐ ២. សៀវភៅគ្រួសារ (ថតចម្លង) ឬសេចក្តីចម្លងសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត ឬលិខិតបញ្ជាក់ទទួលស្គាល់កំណើតរបស់អ្នកស្នើសុំ (ថតចម្លង) | ១សន្លឹក |
| ៦ | **លិខិតបញ្ជាក់កិរិយាមាយាទ** | ☐ ១. អត្តសញ្ញាណបណ្ណ (ថតចម្លង) ឬសេចក្តីចម្លងសំបុត្រកំណើត | ១សន្លឹក |
| | | ☐ ២. សៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ (ថតចម្លង) | ១សន្លឹក |
| ៧ | **លិខិតបញ្ជាក់ប្រវត្តិរូបសង្ខេប** | ☐ ១.សេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើត | ១សន្លឹក |
| | | ☐ ២. សៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ (ថតចម្លង) | ១សន្លឹក |
| | | ☐ ៣. រូបថត ៤x៦ | ១សន្លឹក |
| ៨ | **លិខិតបញ្ជាក់ទិញលក់សត្វពាហនៈ** | ☐ ១. អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនអ្នកទិញ (ថតចម្លង) | ១សន្លឹក |
| | | ☐ ២. អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនអ្នកលក់ (ថតចម្លង) | ១សន្លឹក |
| ៩ | **លិខិតបញ្ជាក់តបណ្តាញអគ្គិសនី** | ☐ ១. ឯកសារសម្គាល់សិទ្ធកាន់កាប់អចលនទ្រព្យ (ថតចម្លង) | ១សន្លឹក |
| | | ☐ ២. សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ (ថតចម្លង) | ១សន្លឹក |
| ១០ | **លិខិតបញ្ជាក់តបណ្តាញទឹកស្អាត** | ☐ ១. ឯកសារសម្គាល់សិទ្ធកាន់កាប់អចលនទ្រព្យ (ថតចម្លង) | ១សន្លឹក |
| | | ☐ ២. សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ (ថតចម្លង) | ១សន្លឹក |
| ១១ | **លិខិតបញ្ជាក់ជួលដី ផ្ទះ តូប យានជំនិះ** | ☐ ១. អត្តសញ្ញាណប័ណ្ណ(ថតចម្លង)(ភាគីទាំងពីរ) | ១សន្លឹក |
| | | ☐ ២. កិច្ចសន្យាជួលដី ផ្ទះ តូប យានជំនិះ | ១ច្បាប់ |
| ១២ | **លិខិតបញ្ជាក់ផ្ទះជួលបន្ទប់ស្នាក់នៅ** | ☐ ១. លិខិតអនុញ្ញាតផ្ទះជួលបន្ទប់ស្នាក់នៅ ប្រសិនបើមាន(ថតចម្លង) ឬរូបថតផ្ទះជួលបន្ទប់ស្នាក់នៅ (រូបថតផ្ទះ និងរូបថតបន្ទប់ស្នាក់នៅទាំងអស់) | ១ច្បាប់ |
| | | ☐ ២. សៀវភៅស្នាក់នៅ (ថតចម្លង) | ១សន្លឹក |

ឧបសម្ព័ន្ធទី៥ ÷ គំរូទម្រង់បែបបទស្នើសុំសេវារដ្ឋបាល

៥.២ ÷ គំរូលិខិតបញ្ជាក់ភាពនៅលីវ មេម៉ាយ ពោះម៉ាយ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រូបថត

4x6

**រាជធានី ខេត្ត ........................**

**ក្រុង ស្រុក ខណ្ឌ......................**

**រដ្ឋបាលឃុំ សង្កាត់....................**

**លេខ....................................**

ថ្ងៃ.........................ខែ.............ឆ្នាំ...........ព.ស ២៥....

................. ថ្ងៃទី........ខែ................ឆ្នាំ ២០.....

**លិខិតបញ្ជាក់**

**☐ ភាពនៅលីវ ☐ មេម៉ាយ ☐ ពោះម៉ាយ**

**យើងមេឃុំ/ចៅសង្កាត់**

សូមបញ្ជាក់ថា ឈ្មោះ..........................................................ភេទ........សញ្ជាតិ........ថ្ងៃខែឆ្នាំកំណើត .......⁄........⁄......... អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ........................................... មុខរបរ................................ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ/អគារ................. ផ្លូវលេខ.................. ភូមិ....................................... ឃុំ/សង្កាត់ ......................................... ក្រុង/ស្រុក/ខណ្ឌ....................................... រាជធានី/ខេត្ត............................ មានស្ថានភាពផ្ទាល់ខ្លួនបច្ចុប្បន្ន ☐ នៅលីវ ☐ មេម៉ាយ ☐ ពោះម៉ាយពិតប្រាកដមែន។

លិខិតបញ្ជាក់នេះចេញជូនសាមីខ្លួនដើម្បីយកទៅប្រើប្រាស់សម្រាប់ ☐ រៀបអាពាហ៍ពិពាហ៍ ☐ បំពេញបែបបទ ចុះបញ្ជី/ផ្ទេរអចលនទ្រព្យ ☐ ..........................................................................................................។

<u>**កំណត់សម្គាល់៖**</u> លិខិតបញ្ជាក់នេះមានសុពលភាពរយៈពេល០៣ខែ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ៕

**មេឃុំ/ចៅសង្កាត់**

ឧបសម្ព័ន្ធទី៥ ÷ គំរូទម្រង់បែបបទស្នើសុំសេវារដ្ឋបាល

៥.៣ ÷ គំរូលិខិតបញ្ជាក់ទីលំនៅ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រូបថត

4x6

**រាជធានី ខេត្ត** ..........................

**ក្រុង ស្រុក ខណ្ឌ**........................

**រដ្ឋបាលឃុំ សង្កាត់**......................

លេខ.....................................

ថ្ងៃ..........................ខែ.............ឆ្នាំ...........ព.ស ២៥....

................. ថ្ងៃទី........ខែ...............ឆ្នាំ ២០.....

**លិខិតបញ្ជាក់ទីលំនៅ**

**យើងមេឃុំ/ចៅសង្កាត់**

សូមបញ្ជាក់ថា ឈ្មោះ.......................................ភេទ........សញ្ជាតិ........ថ្ងៃខែឆ្នាំកំណើត....../....../.......
ទីកន្លែងកំណើតភូមិ..........................ឃុំ/សង្កាត់..................................ក្រុង/ស្រុក/ខណ្ឌ..............................
រាជធានី/ខេត្ត...........................មានអត្តសញ្ញាណប័ណ្ណ/លិខិតឆ្លងដែនលេខ........................... បច្ចុប្បន្នស្នាក់នៅ
☐ផ្ទះបងប្អូន ☐ផ្ទះជួល ☐ផ្សេងៗ........................................................................... មានអាសយដ្ឋាន
នៅផ្ទះលេខ/អគារ......................... ផ្លូវលេខ.................... ភូមិ......................ឃុំ/សង្កាត់..............................
ក្រុង/ស្រុក/ខណ្ឌ.......................................រាជធានី/ខេត្ត......................ពិតប្រាកដមែន។

លិខិតបញ្ជាក់នេះចេញជូនសាមីខ្លួនដើម្បីយកទៅប្រើប្រាស់សម្រាប់.............................................................
...................................................................................................................................................។

<u>**កំណត់សម្គាល់៖**</u> លិខិតបញ្ជាក់នេះមានសុពលភាពរយៈពេល០៣ខែ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ៕

បានឃើញ និងសូមបញ្ជាក់ថា

ឈ្មោះ.............................

ពិតជាមានទីលំនៅក្នុងភូមិ.........................

ឃុំ/សង្កាត់..............................ពិតប្រាកដមែន។

ថ្ងៃទី.........ខែ..........ឆ្នាំ២០.....

**មេភូមិ**

**មេឃុំ/ចៅសង្កាត់**

ឧបសម្ព័ន្ធទី៥ ÷ គំរូទម្រង់បែបបទស្នើសុំសេវារដ្ឋបាល

៥.៤ ÷ គំរូកិច្ចសន្យាខ្ចីប្រាក់

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## កិច្ចសន្យាខ្ចីប្រាក់

កិច្ចសន្យាខ្ចីប្រាក់នេះ ធ្វើឡើងនៅ............ ថ្ងៃទី....... ខែ.............. ឆ្នាំ.........

**រវាង និង រវាង**

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.......................................................ភេទ........សញ្ជាតិ........ថ្ងៃខែឆ្នាំកំណើត ....../....../........កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/លិខិតឆ្លងដែនលេខ.................................................................. មានទីលំនៅបច្ចុប្បន្នផ្ទះលេខ........................ផ្លូវលេខ..................... ភូមិ......................................... ឃុំ/សង្កាត់ .................................... ក្រុង/ស្រុក/ខណ្ឌ................................... រាជធានី/ខេត្ត........................ និងខ្ញុំបាទ/នាងខ្ញុំឈ្មោះ..................................ភេទ........សញ្ជាតិ........ថ្ងៃខែឆ្នាំកំណើត....../....../........កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/លិខិតឆ្លងដែនលេខ........................................... មានទីលំនៅបច្ចុប្បន្នផ្ទះលេខ.......................... ផ្លូវលេខ..................... ភូមិ.............................. ឃុំ/សង្កាត់.......................................... ក្រុង/ស្រុក/ខណ្ឌ .................................. រាជធានី/ខេត្ត..................តទៅនេះហៅថា **«ភាគីក» ឬម្ចាស់បំណុល**

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.......................................................ភេទ........សញ្ជាតិ........ថ្ងៃខែឆ្នាំកំណើត ....../....../........កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/លិខិតឆ្លងដែនលេខ.................................................................. មានទីលំនៅបច្ចុប្បន្នផ្ទះលេខ........................ផ្លូវលេខ..................... ភូមិ......................................... ឃុំ/សង្កាត់ .................................... ក្រុង/ស្រុក/ខណ្ឌ................................... រាជធានី/ខេត្ត........................ និងខ្ញុំបាទ/នាងខ្ញុំឈ្មោះ..................................ភេទ........សញ្ជាតិ........ថ្ងៃខែឆ្នាំកំណើត....../....../........កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/លិខិតឆ្លងដែនលេខ........................................... មានទីលំនៅបច្ចុប្បន្នផ្ទះលេខ.......................... ផ្លូវលេខ..................... ភូមិ.............................. ឃុំ/សង្កាត់.......................................... ក្រុង/ស្រុក/ខណ្ឌ .................................. រាជធានី/ខេត្ត..................តទៅនេះហៅថា **«ភាគីខ» ឬកូនបំណុល។**

«ភាគីក» និង «ភាគីខ» រួមគ្នាចាប់ពីពេលនេះតទៅហៅថា **ភាគីទាំងពីរ ឬ គូភាគី។**

**«ភាគីក» និង «ភាគីខ» បានព្រមព្រៀងគ្នាដោយឆន្ទៈ និងសេរីតាមប្រការដូចខាងក្រោម ៖**

